ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ...........១២៣..........ក.ប/ស.ជ.ណ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរលើកទី១៣

## (13th EPS-TOPIK)

យោងលិខិត EPST-3091 ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ របស់អង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស (HRD-Korea) នៃក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (គ.ប.ប.ព.ប) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់សាធារណជនដែលមានបំណងទៅធ្វើការនៅសាធារណរដ្ឋកូរ៉េ ក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ ឱ្យបានជ្រាបថា អង្គភាព HRD-Korea នឹងរៀបចំការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS-TOPIK) លើកទី១៣ ដែលមានព័ត៌មានលម្អិតដូចខាងក្រោម៖

- **កាលបរិច្ឆេទប្រឡង៖** ថ្ងៃសៅរ៍ ទី២៥ និងថ្ងៃអាទិត្យ ទី២៦ ខែមិថុនា ឆ្នាំ២០១៦។
- **មណ្ឌលប្រឡង** ៖
  - ជម្រាបជូននៅលើកាសែតកម្ពុជាថ្មី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី១៧ ខែមិថុនា ឆ្នាំ២០១៦ បិទផ្សាយនៅក្តារព័ត៌មានរបស់ គ.ប.ប.ព.ប ផ្សាយលើគេហទំព័រ គ.ប.ប.ព.ប http://www.mtosb.gov.kh និងផ្សាយលើហ្វេសប៊ុកផ្លូវការ គ.ប.ប.ព.ប www.facebook.com/mtosbcambodia។
  - ការបែងចែកលេខកូដពាក្យប្រឡងរបស់បេក្ខជន-បេក្ខនារី តាមមណ្ឌលប្រឡងនីមួយៗ គឺត្រូវបានកំណត់ដោយអង្គភាព HRD-Korea។
- **ចំនួនអ្នកប្រឡងជាប់៖** វិស័យឧស្សាហកម្មចំនួន ៤ ៧០០នាក់ វិស័យសំណង់ចំនួន ១ ០០០នាក់ និងវិស័យកសិកម្មចំនួន ៣ ៧០០នាក់។

បេក្ខជន-បេក្ខនារី ដែលប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េ គឺជាបេក្ខជន-បេក្ខនារី ដែលទទួលបានពិន្ទុសរុបលើសពី៨០ពិន្ទុ និងចំណាត់ថ្នាក់ប្រឡងចន្លោះពីទី០១ ដល់ទី៤៧០០ ក្នុងវិស័យឧស្សាហកម្ម ចន្លោះពីទី០១ ដល់ទី១០០០ ក្នុងវិស័យសំណង់ និងចន្លោះពីទី០១ ដល់ទី៣៧០០០ ក្នុងវិស័យកសិកម្ម។

- **បញ្ជាក់៖ បេក្ខជន-បេក្ខនារី ដាក់ពាក្យសុំសិទ្ធិប្រឡងបានតែមួយ និងជ្រើសរើសបានតែមួយវិស័យប៉ុណ្ណោះ។**
- **លក្ខណសម្បត្តិ៖**
  - ត្រូវមានកាយសម្បទាគ្រប់គ្រាន់ និងសុខភាពល្អ
  - ត្រូវមានអាយុចាប់ពី១៨ ដល់ ៣៩ឆ្នាំ (អ្នកដែលមានថ្ងៃខែឆ្នាំកំណើតចន្លោះពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩៨)
  - មិនមានប្រវត្តិប្រព្រឹត្តបទល្មើស មិនធ្លាប់ជាប់ពន្ធនាគារ ឬទោសឧក្រិដ្ឋ
  - មិនធ្លាប់ធ្វើការងារខុសច្បាប់នៅសាធារណរដ្ឋកូរ៉េ ឬបណ្តេញចេញពីសាធារណរដ្ឋកូរ៉េ
  - មិនមានការហាមឃាត់ក្នុងការចាកចេញពីព្រះរាជាណាចក្រកម្ពុជា។

- **កាលបរិច្ឆេទនៃការចែក និងទទួលពាក្យ៖** ចាប់ពីថ្ងៃច័ន្ទ ទី៩ ដល់ថ្ងៃព្រហស្បតិ៍ ទី១២ ខែឧសភា ឆ្នាំ២០១៦។
- **ទីកន្លែងចែក និងទទួលពាក្យ៖**

  ១-វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) មានទីតាំងស្ថិតនៅភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ លេខទូរស័ព្ទទំនាក់ទំនង ០២៣ ៦៥២៥ ៧៧៧/០១២ ៤៦៦ ២២២។

  ២-**មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ចាម** មានទីតាំងស្ថិតនៅភូមិ៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម លេខទូរស័ព្ទទំនាក់ទំនង ០១១ ៤៦៦ ២២២ / ០១១ ៣៨៣ ៧៣៥។

  ៣-**មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង** មានទីតាំងស្ថិតនៅភូមិទួលក្រឡាញ់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង លេខទូរស័ព្ទទំនាក់ទំនង ០១២ ២១៤ ៧០១ /០១៦ ៤៦៦ ២២២។

  ៤-**វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែន តាកែវ** មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ លេខទូរស័ព្ទទំនាក់ទំនង ០៨៨ ៣៥៩៨ ៨៨៨ / ០៩៧ ៨៩១៨ ៧៧៧។
- **ឯកសារពាក់ព័ន្ធដែលត្រូវយកភ្ជាប់មកជាមួយនៅថ្ងៃចែក និងទទួលពាក្យរួមមាន៖**
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (ច្បាប់ដើម និងថតចម្លងពណ៌ធម្មជាតិចំនួន០១ច្បាប់)
  - រូបថតពណ៌ធម្មជាតិដែលមិនមានការតុបតែង ទំហំ ៣.៥ x ៤.៥ សង់ទីម៉ែត្រ (ផ្ទៃខាងក្រោយពណ៌សថតក្នុងអំឡុងពេល០៣ខែថ្មីៗនេះ) ចំនួន០២សន្លឹក។
- **តម្លៃសុំសិទ្ធិប្រឡងជូនទៅអង្គភាពអភិវឌ្ឍន៍ធនធានមនុស្ស** (HRD-Korea) **នៃក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ៖ ២៤ដុល្លារ** (US$24)។
- **វិញ្ញាសាប្រឡង៖** វិញ្ញាសាអានមាន ២៥សំណួរ (រយៈពេល៤០នាទី) និងវិញ្ញាសាស្តាប់មាន ២៥សំណួរ (រយៈពេល៣០នាទី)។ វិញ្ញាសាទាំងពីរនឹងអនុវត្តបន្តបន្ទាប់គ្នាដោយពុំមានការឈប់សម្រាកឡើយ។
- **ឯកសារ និងសម្ភារៈដែលត្រូវយកមកជាមួយនៅថ្ងៃប្រឡង៖**
  - បង្កាន់ដៃសុំសិទ្ធប្រឡង
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនច្បាប់ដើម (ដូចគ្នាទៅនឹងឯកសារបានបិទលើពាក្យសុំសិទ្ធិប្រឡង)
  - ប៊ិចទឹកពណ៌ខ្មៅសម្រាប់បំពេញរង្វង់ចម្លើយ (មានតែប៊ិចទឹកពណ៌ខ្មៅប៉ុណ្ណោះដែលអនុញ្ញាតឱ្យប្រើនៅពេលប្រឡង)។
- **ការប្រកាសលទ្ធផល៖**

  ១- កាលបរិច្ឆេទនៃការប្រកាសលទ្ធផល៖ ថ្ងៃពុធ ទី១៣ ខែកក្កដា ឆ្នាំ២០១៦

  ២- លទ្ធផលប្រឡងនឹងបិទផ្សាយនៅតាមមណ្ឌលប្រឡង គេហទំព័រ www.eps.go.kr **របស់អង្គភាព** HRD-Korea បិទផ្សាយនៅក្តារព័ត៌មាន គ.ប.ប.ព.ប ផ្សាយលើគេហទំព័រ គ.ប.ប.ព.ប http://www.mtosb.gov.kh និងផ្សាយលើហ្វេសប៊ុកផ្លូវការរបស់ គ.ប.ប.ព.ប www.facebook.com/mtosbcambodia។
- **ព័ត៌មានផ្សេងៗ**
  - នៅថ្ងៃប្រឡងមិនអនុញ្ញាតឱ្យយកចូលក្នុងបន្ទប់ប្រឡងនូវទូរស័ព្ទដៃ ម៉ាញេចាក់កាសែត PDA, MP3 Player, វចនានុក្រមអេឡិចត្រូនិច និងឧបករណ៍អេឡិចត្រូនិចផ្សេងទៀត ដែលអាចប្រើក្នុងការលួចបន្លំ។
  - ការប្រឡងតេស្តនឹងចាត់ទុកជាមោឃៈ ហើយបេក្ខជន នឹងមិនអនុញ្ញាតឱ្យដាក់ពាក្យសុំសិទ្ធិប្រឡងតេស្តក្នុងរយៈពេល០២ឆ្នាំ ក្នុងករណីដែលមានការលួចបន្លំក្នុងពេលប្រឡង។
  - ប្រសិនបើព័ត៌មានផ្ទាល់ខ្លួន (ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងភេទ) របស់បេក្ខជននៅលើអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនមិនដូចគ្នានឹងព័ត៌មាននៅលើពាក្យសុំសិទ្ធិប្រឡងទេ នោះបេក្ខជននឹងមិនត្រូវបានចុះ

ឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកស្វែងរកការងារធ្វើក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ EPS ក៏ដូចជាការបញ្ជូនទៅសាធារណរដ្ឋកូរ៉េឡើយ។ បេក្ខជនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះបញ្ហា ដែលបណ្តាលមកពីភាពខុសគ្នានៃព័ត៌មានទាំងនោះ។

- ការប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េ មិនមានន័យថា បានប្រឡងជាប់ទៅធ្វើការនៅសាធារណរដ្ឋកូរ៉េឡើយ។
- បេក្ខជនដែលធ្លាក់តេស្តសុខភាព ឬធ្លាប់ស្នាក់នៅដោយខុសច្បាប់នៅសាធារណរដ្ឋកូរ៉េ មិនត្រូវបានអនុញ្ញាតឱ្យដាក់ពាក្យសុំទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េឡើយ បើទោះបីជាបានប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េក៏ដោយ។
- យោងអនុស្សរណៈយោគយល់ស្តីពីការបញ្ជូនពលករក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ EPS មានតែគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេសតែប៉ុណ្ណោះ ដែលមានសិទ្ធិបញ្ជូនពលករកម្ពុជាទៅធ្វើការងារនៅសាធារណរដ្ឋកូរ៉េ។ មានតែបេក្ខជនដែលបានប្រឡងជាប់តេស្តសមត្ថភាពភាសាកូរ៉េ EPS-TOPIK និងបានចុះឈ្មោះចូលក្នុងបញ្ជីស្វែងរកការងារធ្វើប៉ុណ្ណោះ ដែលអាចត្រូវបានជ្រើសរើសដោយនិយោជកកូរ៉េតាមរយៈប្រព័ន្ធកុំព្យូទ័រ។ ភ្នាក់ងារឯកជនណាមួយ ដែលជាប់ពាក់ព័ន្ធនៅក្នុងដំណើរការបញ្ជូនពលករ នឹងត្រូវធ្វើការជាកពិន័យតាមច្បាប់ជាធរមាន។
- ការប្រឡងតេស្តសមត្ថភាពភាសាកូរ៉េនេះ រៀបចំដោយ ក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ និងអនុវត្តដោយអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ ដោយមានការសហការជាមួយគណៈកម្មាធិការបណ្តុះ-បណ្តាល និងបញ្ជូនពលករទៅបរទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ដែលមានទីតាំងស្ថិតនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទមណ្ឌលនីមួយៗខាងលើ រៀងរាល់ម៉ោងធ្វើការ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៦

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការ

បណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស

ពេជ សោភ័ន

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងមហាផ្ទៃ

-សាលាខេត្តពាក់ព័ន្ធ "ដើម្បីជ្រាប និងសហការ"

-គ្រប់ស្ថាប័ន និងក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"

-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

"ដើម្បីជួយផ្សព្វផ្សាយ និងសហការ"

-ឯកសារ-កាលប្បវត្តិ